K03369
TSL Box4

ករណី **ភូង**

- អាយុ ២៨ ។ ប្រុស ។ ខ្មែរ ។ មានគ្រួសារ ។

. អតីត . កម្មកររោងចក្រ ទង់ទ្បាន តាខ្មៅ ។

- បច្ចុប្បន្ន . កម្មករ . ក.១ .

. នៅក្នុងរោងចក្រ មានការទាក់ទងទទួលឥទ្ធិពល និង ការអប់រំនយោបាយ ប្រឆាំង កុម្មុយនីស ប្រឆាំងបដិវត្តកម្ពុជា ពីឈ្មោះ ស៊ាង.គឹមឡៀក - " សេអ៊ីអា នាយផ្នែកផលិតកម្ម . បច្ចុ. មិនដឹង " និង ពិត.ថា " សេអ៊ីអា នាយក្រសួងផលិតកម្ម . បច្ចុ. មិនដឹង " និង ពិន.ថុន " សេអ៊ីអា បច្ចុ. ចាប់ខ្លួន " រហូតព្រមចូលបំរើ អង្គការ សេអ៊ីអា ។

១៩៧២ - ចូល សេអ៊ីអា នៅរោងចក្រ កង់ទ្បាន តាខ្មៅ

អ្នកនាំចូល ស៊ាង.គឹមឡៀក

អ្នកទទួលស្គាល់ ពិន.ថុន

ប្រាក់ខែ ២ ម៉ឺនរៀល - មុនដំបូង -

ភារកិច្ច ឃោសនាប្រឆាំងកុម្មុយនីស ប្រឆាំងខ្មែរក្រហម . ពង្រីកកម្លាំង សេអ៊ីអា និង ដើរស៊ើបការ រកបណ្តាញ ខ្មែរក្រហម ទាំងក្នុង និង ក្រៅរោងចក្រ ។

សកម្មភាព . ក្រោយ ១៧.៤.៧៥

- បានភ្ជាប់ខ្សែរយៈ សេអ៊ីអា ជាមួយ ពិនថុន ហើយធ្វើសកម្មភាពក្នុងក្រុម ប្រាក់.សារី--បច្ចុប្បន្ន បាត់ខ្លួន - ។
- បានឃោសនា វាយប្រហារអង្គការ បដិវត្ត ថា ផ្ដាច់ការ បំបិតសិទ្ធិ សេរីភាព ធ្វើឱ្យ ប្រទេសជាតិ និង ប្រជាជនធ្លាក់ ក្រតោកយ៉ាក ខែទំនាស់រវាងកម្មករចាស់ និង អង្គការ និង កម្មករថ្មី ឱ្យកម្មករចាស់ មិនទុកចិត្ត អង្គការ លាក់ចំណេះ បច្ចេកទេស វាយប្រហារកម្មាភិបាល ថា រស់នៅ ស៊ីចុក និង ធ្វើការងារ មិនស្មើភាព ។
- បានធ្វើការមិនទទួលខុសត្រូវ ដូចជាធ្វើឱ្យ អន់គុណភាព កង់ឡាន ដោយ ដាក់កំដៅ សម្រាប់ធ្វើក្រឡា មិនត្រឹមត្រូវ ។